**BMI0182**

# សម្ភាសជាមួយឈ្មោះ មិ ម៉ៅ ភេទស្រី អាយុ៩៦ឆ្នាំ

## មុខងារខ្មែរក្រហមៈ "នៅចល័តតំបន់"

ស្រុកកំណើតនៅភូមិដូនជ្រែង ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ

សព្វថ្ងៃរស់នៅភូមិស្រះកើត ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ

ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១១

សម្ភាសន៍ដោយៈ សុខ វណ្ណៈ

០០:៤៦:៤៧

ទំព័រ២៥

វណ្ណៈ : អញ្ចឹងថ្ងៃហ្នឹងថ្ងៃទី១៨ ខែ០៦ ឆ្នាំ២០១១ អញ្ចឹងខ្ញុំឈ្មោះ សុខ វណ្ណៈ ម៉ោ ពីអង្គការមជ្ឈមណ្ឌលឯកសារកម្ពុជាណាមីងណាស់ ហើយខ្ញុំម៉ោភូមិឃុំនេះគឺចង់ដឹង ពីរឿងរ៉ាវដែលទាក់ទងនឹងអាងត្រពាំងថ្ម ថានៅក្នុងចន្លោះឆ្នាំ១៩៧៥ដល់៧៩ហ្នឹងគេ ប្រជាជនយើងនៅក្នុងតំបន់៥ហ្នឹង ទៅធ្វើអាងត្រពាំងថ្មហ្នឹងមានប៉ុន្មានស្រុកប៉ុន្មានអីអញ្ចឹង ហើយពួកគាត់ធ្វើអាងត្រពាំងថ្មហ្នឹង បានជួបបញ្ហាអីខ្លះកើតឡើងនៅក្នុងសម័យហ្នឹង អញ្ចឹងជាដំបូងខ្ញុំចង់សួរឈ្មោះមីង មីងឈ្មោះអីទៅ?

ម៉ៅ : ឈ្មោះ មិ ម៉ៅ ។

វណ្ណៈ : មីងអាយុប៉ុន្មានហើយ?

ម៉ៅ : អាយុ៩៦ ។

វណ្ណៈ : ប្ដីមីងឈ្មោះអី?

ម៉ៅ : ប្ដីងាប់ពីសម័យ៣ឆ្នាំហើយ ។

វណ្ណៈ : បាទ!ប៉ុន្តែឈ្មោះអីទៅ?

ម៉ៅ : ចេង យ៉េត ។

វណ្ណៈ : ស្លាប់សម័យ៣ឆ្នាំ គាត់ស្លាប់ដោយសារអី?

ម៉ៅ : មិនដឹងយ៉ាងណា ។

វណ្ណៈ : មីងអត់ដឹងថាគាត់ស្លាប់ដោយសារអីទេ?

ម៉ៅ : គេហៅទៅៗក៏បាត់ទៅ ។

វណ្ណៈ : ហើយមានកូនប៉ុន្មានមីងរាល់ថ្ងៃ?

ម៉ៅ ៖ កូន១នាក់ ។

វណ្ណៈ ៖ កូនតែ១ទេ មីងអត់មានប្តីក្រោយទៀតទេ?

ម៉ៅ ៖ អត់ ។

វណ្ណៈ ៖ អ្ហូ!ឥឡូវកូនហ្នឹងធំហើយ?

ម៉ៅ ៖ កូនមានគ្រួសារហើយ នេះចៅ ។

វណ្ណៈ ៖ ចុះស្រុកកំណើតមីងនៅភូមិអី?

ម៉ៅ ៖ ភូមិដូនជ្រែង ។

វណ្ណៈ ៖ ឃុំ?

ម៉ៅ ៖ ព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ។

វណ្ណៈ ៖ ឥឡូវខេត្តបន្ទាយមានជ័យ កាលពីដើមខេត្តបាត់ដំបង?

ជិតខាង ៖ បាទ!ខេត្តបាត់ដំបងត្រូវហើយ ។

វណ្ណៈ ៖ ចុះឪពុកមីងឈ្មោះអីដែរ?

ម៉ៅ ៖ ឈ្មោះមិ ។

វណ្ណៈ ៖ ត្រកូលគាត់ មីងនិយាយទាំងត្រកូលគាត់ផង?

ម៉ៅ ៖ អត់ស្គាល់ទេ ។

វណ្ណៈ ៖ ម្តាយឈ្មោះ?

ម៉ៅ ៖ ហាច ។

វណ្ណៈ ៖ អត់ស្គាល់ត្រកូលដែរ?

ម៉ៅ ៖ មិនដឹងឈ្មោះអី?

វណ្ណៈ ៖ សព្វថ្ងៃគាត់ទាំងពីរស្លាប់ហើយ?

ម៉ៅ ៖ ស្លាប់ហើយ ស្លាប់យូរណាស់ហើយតាំងខ្ញុំនៅតូចៗ ។

វណ្ណៈ ៖ ស្លាប់ជំនាន់ណាទៅ?

ម៉ៅ ៖ ស្លាប់ពីខ្ញុំនៅធំជាងនេះបន្តិច ។

វណ្ណៈ ៖ ស្លាប់តាំងជំនាន់ទម្លាក់គ្រាប់បែកអី?

ម៉ៅ ៖ យូរណាស់ហើយ មិនដឹងជាអន្តរាល់ណាទេ តាំងពីខ្ញុំអាយុប្រហែលជា១០ឆ្នាំហ្នឹង ហើយ ។

វណ្ណៈ ៖ អញ្ចឹងសម័យសម្តេចសីហនុ?

ម៉ៅ ៖ ប្រហែលហ្នឹងមិនដឹងខ្ញុំអត់ចាំទេ ។

វណ្ណៈ : ចុះមីងមានបងប្អូនប៉ុន្មាននាក់?

ម៉ៅ : បងប្អូនខ្ញុំនេះងាប់អស់ នៅតែម្នាក់ ។

វណ្ណៈ : ទាំងអស់មានប៉ុន្មាន?

ម៉ៅ : មាន៥នាក់ នៅសល់តែម្នាក់ទេឥឡូវហ្នឹង ។

វណ្ណៈ : មីងកូនទីប៉ុន្មាន?

ម៉ៅ : កូនពៅគេ កូនទី៥ ។

វណ្ណៈ : ចុះ៤នាក់ទៀតស្លាប់ដោយសារអី?

ម៉ៅ : ឈឺខ្លួនឯង ងាប់ខ្លួនឯង ។

វណ្ណៈ : ស្លាប់ក្រោយ៧៩នេះអី?

ម៉ៅ : អត់ទេងាប់មុននោះខ្លះ ងាប់ក្រោយនេះដែលវៀតណាមចូលនេះ២នាក់ ។

វណ្ណៈ : បាទ!ចុះសម័យខ្មែរក្រហមមានស្លាប់ទេ?

ម៉ៅ : សម័យខ្មែរក្រហមអត់មានស្លាប់ទេ ។

វណ្ណៈ : មុនសម័យខ្មែរក្រហម?

ម៉ៅ : ចា៎!

វណ្ណៈ : សម័យប៉ុល ពតអត់មានទេ?

ម៉ៅ : អត់មានទេ មានតែប្តី ។

វណ្ណៈ : ចុះមីងបានរៀនសូត្រទេកាលពីតូច?

ម៉ៅ : រៀនថ្នាក់ទី១២កាលពីសម័យនោះ ដល់មកដល់ទី១១ទៅក៏ម៉ែឪអត់ក៏មិនដែលបាន រៀនទេ ក៏ឈឺទៅក៏អត់មិនចេះអក្សរទេ ។

វណ្ណៈ : ឈប់រៀនដោយសារអី?

ម៉ៅ : ម៉ែឪអត់ ឈឺទៅក៏ឈប់រៀន ។

វណ្ណៈ : ហើយគាត់ស្លាប់ចោលតាំងមីងអាយុ១០ឆ្នាំ?

ម៉ៅ : ចា៎!

វណ្ណៈ : អញ្ចឹងមីងពេលមីងឈប់រៀនហើយមីងទៅណា មីងទៅធ្វើអីទៅ?

ម៉ៅ : អត់ធ្វើអីទេ ។

វណ្ណៈ : ធ្វើស្រែចំការ ឬទៅស៊ីឈ្នួលគេ ឬទៅ?

ម៉ៅ : ចា៎!ទៅស៊ីឈ្នួលគេ ។

វណ្ណៈ : ស៊ីឈ្នួលពីណាគេ នៅណា?

ម៉ៅ : នៅក្នុងភូមិនេះឯង ។

វណ្ណៈ : ស៊ីឈ្នួលរហូតដល់ឆ្នាំណាបានខ្មែរក្រហមចូលស្រុក?

ម៉ៅ : មិនបានប៉ុន្មានទេ ឆ្នាំប៉ុន្មានទេខ្ញុំធំហើយហ្នឹង ខ្មែរក្រហមមិនដឹងឆ្នាំណា ខ្ញុំមិនចាំទេ ។

វណ្ណៈ : ចុះសម័យទម្លាក់គ្រាប់បែកគ្រាប់អី កាលហ្នឹងមីងមានដឹងខ្លះៗទេ?

ម៉ៅ : សម័យទម្លាក់គ្រាប់បែករត់ផ្អើលដឹងហើយ នៅនេះឯង ទម្លាក់ផាត់សុដងនេះឯង ។

វណ្ណៈ : ទម្លាក់នៅភូមិណា?

ម៉ៅ : ទម្លាក់ផាត់សុដងនោះ ។

វណ្ណៈ : បាទ!ទម្លាក់គ្រាប់បែកៗដល់ចប់ស្ងប់ទម្លាក់គ្រាប់បែកហ្នឹង ខ្មែរក្រហមចេញចូលក្នុងភូមិហ្នឹងជាមួយទាហានលន់ ណុលអីមានទេនៅហ្នឹង?

ម៉ៅ : មាន ។

វណ្ណៈ : មាន អញ្ចឹងដល់ពេលខ្មែរក្រហមចូលម៉ៅឆ្នាំ៧៥នេះ មីងធ្វើអីទៀត?

ម៉ៅ : អត់ ។

វណ្ណៈ : ចុះខ្មែរក្រហមអត់ប្រើមីងទេ ដែលរំដោះហើយ?

ម៉ៅ : អ្ហូ!ខ្ញុំទៅលើកដីនោះឯង ទៅចល័ត ។

វណ្ណៈ : ទៅដំបូង៧៥ចូលចល័តហ្មង?

ម៉ៅ : ចា៎!

វណ្ណៈ : ចូលចល័តស្រុក ឬក៏ចល័តតំបន់?

ម៉ៅ : តំបន់ តាវ៉ាល់ សុំគេនៅ២-៣ថ្ងៃគេមិនឲ្យនៅទេ ឲ្យទៅ ។

វណ្ណៈ : តាវ៉ាល់ហ្នឹងតួនាទីគាត់ធ្វើអីគេ គាត់គណៈតំបន់ឬអី?

ម៉ៅ : ធ្វើគណៈតំបន់ដឹង ឮតែគេថាដែរ គណៈតំបន់ហ្នឹងក្តោបក្តាប់ ។

វណ្ណៈ : ក្រៅពីតាវ៉ាល់ ស្គាល់ពីណាទៀត?

ម៉ៅ : អត់ទេ ។

វណ្ណៈ : ទៅនៅជាមួយតាវ៉ាល់ តាំងពី៧៥ម៉ៅ?

ម៉ៅ : ចា៎!

វណ្ណៈ : អញ្ចឹងពេលទៅនៅជាមួយតាវ៉ាល់ នៅ៧៥ហ្នឹងតើដំបូងមីងទៅធ្វើអីគេ ចល័តហ្នឹងធ្វើអីទៅ?

ម៉ៅ : លើកដីហ្នឹង ។

វណ្ណៈ : លើកដីលើកនៅណា?

ម៉ៅ : នៅស្រេះ ។

វណ្ណៈ : នៅស្រេះ ដំបូងនៅស្រេះ?

ម៉ៅ : ចា៎!

វណ្ណៈ : ស្រេះហ្នឹងគេលើកទំនប់ ឬក៏លើកប្រឡាយ?

ម៉ៅ : លើកទំនប់ផង លើកប្រឡាយផង លើកពីស្រេះទៅកំបោរ ។

វណ្ណៈ : កាលហ្នឹងលើកទំនប់ ហើយធ្វើស្រែដកស្ទូង?

ម៉ៅ : ទេ!អត់បានធ្វើស្រែទេ លើកតែដី ។

វណ្ណៈ : លើកទំនប់រហូត?

ម៉ៅ : ចា៎!

វណ្ណៈ : ទំនប់ហ្នឹងទំនប់ប៉ុនណាទៅ?

ម៉ៅ : ដូចជាទទឹង៥មិនដឹង ខ្នងលើដូចជា៥ ។

វណ្ណៈ : ទទឹង៥ម៉ែត្រ កម្ពស់?

ម៉ៅ : កម្ពស់អត់ដឹងទេ ។

វណ្ណៈ : បណ្តោយដឹងទេ?

ម៉ៅ : បណ្តោយទៅដល់កំបោរហ្នឹង ពីស្រេះទៅកំបោរ ។

វណ្ណៈ : ប៉ុន្មានគីឡូទៅ?

ម៉ៅ : មិនដឹងទេ ។

វណ្ណៈ : ទេដល់កំបោរ មីងលើកនៅហ្នឹងគេមានវាស់ម៉ែត្រគីបដែរឬអត់?

ម៉ៅ : វាស់ ។

វណ្ណៈ : ប៉ុន្មានម្នាក់?

ម៉ៅ : ៧ម៉ែត្រគីប ។

វណ្ណៈ : ហើយទេមើលទៅ?

ម៉ៅ : ហើយថ្ងៃណា ថ្ងៃណាអត់ហើយទេ ។

វណ្ណៈ : ចុះបើអត់ហើយធ្វើម៉េច?

ម៉ៅ : អត់ហើយ គេថាខ្វះអញ្ចឹងទៅ ។

វណ្ណៈ ៖ បាទ!គេឲ្យហូបអី?

ម៉ៅ ៖ បាយហ្នឹង ។

វណ្ណៈ ៖ កាលហ្នឹងជំបូង៧៥អត្តូវទ់ពិបាកទេ?

ម៉ៅ ៖ ចា៎!

វណ្ណៈ ៖ ចុះមីងកាលហ្នឹងមីង ដូចថាកាន់កងគ្នាប៉ុន្មានប្ុនៅ?

ម៉ៅ ៖ អត់ទេ ។

វណ្ណៈ ៖ អត់ទាន់កាន់ទេ?

ម៉ៅ ៖ ចា៎!

វណ្ណៈ ៖ បាទ!អញ្ចឹងមីងនៅសមាជិកនៅឡើយទេ?

ម៉ៅ ៖ ចា៎!

វណ្ណៈ ៖ ពីណាប្រធានមីអទៅជំបូងៗ ឆ្នាំ៧៥?

ម៉ៅ ៖ ជំបូងអ្នកសេនាជនគេ ។

វណ្ណៈ ៖ ពួកភ្នំពេញម៉ោប្ុនៅកាលហ្នឹង?

ម៉ៅ ៖ នៅ ។

វណ្ណៈ ៖ ពួកប្រជាជនថ្មី?

ម៉ៅ ៖ អ៊ូ!ម៉ោហើយ ។

វណ្ណៈ ៖ ប្រជាជនថ្មីម៉ោខ្លះៗហើយ ចុះមីងលើកនៅទំនប់ហ្នឹងគេហៅទំនប់អីទៅ ទំនប់ដែលមីង លើកហ្នឹងគេហៅទំនប់ឈ្មោះអីទៅ?

ម៉ៅ ៖ ទំនប់អូររន្ទះបាញ់ ។

វណ្ណៈ ៖ គេដាក់ឈ្មោះអញ្ចឹងហ្មង ទំនប់អូររន្ទះបាញ់អញ្ចឹងហ្មង?

ម៉ៅ ៖ ចា៎!ហ្នឹងហើយ ។

វណ្ណៈ ៖ អញ្ចឹងទៅហ្នឹងតាវ៉ាល់អី គាត់ទៅគ្រប់គ្រងដែរ?

ម៉ៅ ៖ ចា៎!

វណ្ណៈ ៖ គាត់ខស្សាហ៍ទៅមើលដែរ?

ម៉ៅ ៖ គាត់នៅធ្វើជំរុំនៅក្បែរស្រែះនេះឯង ។

វណ្ណៈ ៖ ហើយពេលព្រឹកម៉ោងប៉ុន្មានចូលធ្វើការ?

ម៉ៅ ៖ ម៉ោង៧ហ្នឹង ម៉ោង១១ឡើង ។

វណ្ណៈ : ចុះវិញ?

ម៉ៅ : ម៉ោង១ចុះ ម៉ោង៥ឡើង ។

វណ្ណៈ : បាទ!អញ្ចឹងកាលនៅធ្វើទំនប់ហ្នឹង មានជនជាតិចិន មានអីទៅមើលទេកាលហ្នឹង ?

ម៉ៅ : អត់មានទេ ។

វណ្ណៈ : មីងធ្វើទំនប់ហ្នឹងរយៈពេលប៉ុន្មានឆ្នាំទៅ?

ម៉ៅ : អេ៎!មិនដឹងប៉ុន្មានទេ យូរគ្រាន់ ប៉ុន្មានទេខ្ញុំមិនចាំ ។

វណ្ណៈ : ធ្វើប្រហែលមួយឆ្នាំដែរទេ?

ម៉ៅ : បែបជាងមួយឆ្នាំទៅដឹង បើទំនប់ស្រះព្រះនេត្រព្រះស្រះម៉ោ បានម៉ោនេះទៀត ។

វណ្ណៈ : ប្រជាជនប្រហែលប៉ុន្មាននាក់ទៅ?

ម៉ៅ : ប្រជាជនច្រើនដែរ ប្រហែល៧-៨០០ទៅ១០០០នាក់ទេដឹង ហើយទំនប់ចល័តមិនដែលដឹងគ្នាទេ មើលមុខគ្នាមិនបានផង ។

វណ្ណៈ : អញ្ចឹងកងមីងមានគ្នាប៉ុន្មាននាក់ មា៉ក្រុមមីងដាច់ពីគេ?

ម៉ៅ : មា៉ក្រុម១០នាក់ ។

វណ្ណៈ : មា៉ក្រុម១០នាក់ ហើយចុះមា៉ដូចថាមា៉វរៈរបស់មីងហ្នឹងពីអ្នកគ្រប់គ្រង?

ម៉ៅ : ដូចសេនាជនគេ ប៉ុនមិនដឹងឈ្មោះអី ។

វណ្ណៈ : អ៊ូ!សេនាជនគ្រប់គ្រង?

ម៉ៅ : ចា៎!

វណ្ណៈ : បាទ!ដល់ពេលឆ្នាំណាបានសេនាជនឈប់គ្រប់គ្រង ឲ្យយើងបែកចែកតាមកម្លាំងនារីគាត់កាន់កាប់អីអញ្ចឹង?

ម៉ៅ : ចា៎!មានអ្នកចាស់ មានអ្នកថ្មី គេអ្នកចាស់គេក្តាប់អកថ្មីម៉ោ រួចចេញពីទំនប់កំបោរស្រះរួចបានទៅនៅទំនប់ត្រពាំងថ្ម ។

វណ្ណៈ : មីងមានចាំទេថាទៅទំនប់ត្រពាំងថ្មប្រហែលជាឆ្នាំណា?

ម៉ៅ : ខ្ញុំអត់ចាំទេ ។

វណ្ណៈ : អញ្ចឹងនៅនេះប្រហែល១ឆ្នាំ?

ម៉ៅ : ចា៎!

វណ្ណៈ : អញ្ចឹងប្រហែលជា៧៦?

ម៉ៅ : ចា៎!

វណ្ណៈ :   ៧៦មីងទៅអាងត្រពាំងថ្ម?

ម៉ៅ :   ចា៎!

វណ្ណៈ :   ទៅដល់ដំបូងគេឲ្យមីងធ្វើអី?

ម៉ៅ :   គេគ្មានធ្វើអី ទៅដល់គេឲ្យលើកដីហ្នឹង ។

វណ្ណៈ :   លើកដីដែរ?

ម៉ៅ :   ចា៎!

វណ្ណៈ :   គាវ៉ាល់ទៀត គាអ្នកគ្រប់គ្រង?

ម៉ៅ :   ចា៎!

វណ្ណៈ :   បាទ!អញ្ចឹងទៅអាងត្រពាំងថ្មគេដាក់ករិត២គីបដដែលឬគេបន្ថែម៣គីប?

ម៉ៅ :   ២គីបដដែល ។

វណ្ណៈ :   ២គីបហ្នឹងគេសម្រាប់កម្លាំងយ៉ាងម៉េច?

ម៉ៅ :   កម្លាំងអី ម្នាក់២គីបៗគ្រប់តែគ្នាអញ្ចឹងទៅ បើថាមិនរួចទេបានដាង១គីបដដែល ។

វណ្ណៈ :   ប៉ុន្តែមានកន្លែងខ្លះគេថា នៅកន្លែងអាងត្រពាំងថ្មគេបែងចែកជា៣ ដូចថាកម្លាំងទី១ ៣ គីប កម្លាំងទី២ ២គីប និងកម្លាំងទី៣ហ្នឹងមនុស្សដូចថាមនុស្សវ៉ាខ្សោយទៅ ម៉ាគីបកន្លះក្នុង១ថ្ងៃ អញ្ចឹងមែនក៏អី?

ម៉ៅ :   ចា៎!អញ្ចឹងឯង ប៉ុនថាស្រីនឹងប្រុសនេះមិនដែលបានទៅនិយាយគ្នាទេ បើនិយាយទល់បេះគេថា យើងខុសសីលធម៌ ។

វណ្ណៈ :   បាទ!អញ្ចឹងក្មេងសួរមីងបន្តិចកន្លែងអូររន្ទះបាញ់ហ្នឹង កាលសម័យ៧៥ហ្នឹងមានស្លាប់មនុស្សមានអីដែរ?

ម៉ៅ :   អត់ដឹងទេ ។

វណ្ណៈ :   អត់ដឹងទេ?

ម៉ៅ :   ចា៎!

វណ្ណៈ :   អញ្ចឹងម៉ៅត្រពាំងថ្មហ្នឹង?

ម៉ៅ :   ត្រពាំងថ្មក៏ខ្ញុំមិនដឹង ព្រោះវរល់តែភ័យរស់រៀងខ្លួន ខ្លាចតែធ្វើការមិនរួចឲ្យគេ ក៏គេសម្លាប់ចោលក៏មិនដឹង បេះតែខ្លាច បេះតែខំទៅ ។

វណ្ណៈ :   ចុះមីងពេលមីងទៅអាងត្រពាំងថ្មមីងមានកាន់ក្រុម កាន់អីគេខ្លះទេ?

ម៉ៅ :   ខ្ញុំកាន់៣០នាក់ ។

វណ្ណៈ : អាហ្នឹងកាន់៣០នាក់ហ្នឹងគេហៅប្រធានអី?

ម៉ៅ : ប្រធានកងតូច ។

វណ្ណៈ : បាទ!អញ្ចឹងមីងទៅអាងត្រពាំងថ្មហ្នឹងខ្ញុំឮថាគេមានទៅច្រើនស្រុកណាស់ដែលទៅលើក នៅហ្នឹង?

ម៉ៅ : ទៅច្រើន ប៉ុនខ្ញុំនៅអត់បានយូរ ខ្ញុំនៅបានតែ៣ខែ ខ្ញុំមកបើកវគ្គ ក៏ម៉ៅនៅឯជប់នេះបាត់ ។

វណ្ណៈ : បាទ!មីងទៅរយៈពេល៣ខែហ្នឹង តើមីងឃើញមានដូចថាពីណាខ្លះដែលទៅត្រួតពិនិត្យមើលអាងត្រពាំងថ្មហ្នឹង អ្នកធំ?

ម៉ៅ : ចាំ!មិនដែលឃើញទេ ។

វណ្ណៈ : អត់ដែលឃើញទេ ចុះពីណាបញ្ជាមីងឲ្យធ្វើអញ្ចឹង?

ម៉ៅ : គាវ៉ាល់ហ្នឹង ។

វណ្ណៈ : ចុះម្នាក់មីងកាន់៣០នាក់ហ្នឹង ដូចថា៣០នាក់មានបាក់កម្លាំងស្លាប់អីអត់មានទេ?

ម៉ៅ : អត់ទេ កន្លែងខ្ញុំ បែកគ្នារហូតម៉ៅ ។

វណ្ណៈ : អញ្ចឹងអ្នក១៧មេសាទៅច្រើនទេ?

ម៉ៅ : ទៅច្រើន ។

វណ្ណៈ : អញ្ចឹងឮថាអ្នក១៧មេសាអី មិនសូវចេះធ្វើការអីអញ្ចឹងទៅ ហើយដោយសារអត់ អាហារអត់ទឹកផង បាយគេឲ្យម៉ាចានៗអីអញ្ចឹង ហូបមិនគ្រប់គ្រាន់គ្មានទឹក គ្មានអី មានស្លាប់មីងបានដឹងទេ មីងឮ?

ម៉ៅ : អត់ទេ!មិនបានដឹងទេ ព្រោះខ្ញុំនៅចល័តដូចមិនដែលឃើញមានអ្នកណាសម្លាប់មនុស្ស ផងបើថាច្រើនផាប់ដូចថានៅ តាមភូមិទេដែលអត់ទៅ នៅចល័តនោះមិនសូវអីទេបើយ៉ាប់តែទឹក បាយមិនអីទេ យ៉ាប់តែទឹកប៉ុណ្ណោះឯង ទឹកអត់ ។

វណ្ណៈ : មនុស្សនៅចល័តហ្នឹងប្រហែលជាប៉ុន្មាននាក់ទៅ?

ម៉ៅ : យី!គេនិយាយដូចជា២០០០ទេដឹង មានប្រុសមានស្រីមនុស្សរាប់ពាន់ បើមិនដែលដឹងថាប៉ុន្មាន ។

វណ្ណៈ : បើតាមដឹងគេថា នៅអាងត្រពាំងថ្មហ្នឹងមានស្លាប់មនុស្សច្រើនដែរ ខ្លះគេយកទៅវ៉ៃ ចោលខ្លះដោយសារតែឈឺទៅគេយកមកពេទ្យស្លាប់អញ្ចឹងទៅ តែមីងអត់ឮគេ និយាយឮអីទេ?

ម៉ៅ ៖ ទេ! កាលហ្នឹងដូចថានៅនោះមិនសួរដឹងមិនសួរព្រួយរៀនខ្លួនទេ អ្នកណាឈឺក៏គេយកទៅ ក៏ទៅ អកនៅក៏ធ្វើការទៅ ។

វណ្ណៈ ៖ បាទ!អានេះយើងនិយាយតែអ្វីដែលយើងដឹងការពិតទៅ គឺគេមិនទៅ ដូចថាសួរមីង ហ្នឹងគឺក្នុងន័យថា បើមិនបានឃើញក៏អាចដឹងព្រួដែរ ព្រោះអីនៅក្នុងសម័យហ្នឹងស្លាប់ មនុស្សច្រើនណាស់?

ម៉ៅ ៖ ចា៎!ច្រើន ។

វណ្ណៈ ៖ មនុស្សគរក្បាលឆ្អឹងទាំងគ្រប់ខេត្ត ចុះបើមីងថាអត់ស្លាប់អញ្ចឹងវាមានមនុស្សនៅដដែល អញ្ចឹងចង់និយាយថា មិនមែនឲ្យមីងនិយាយប្រលើសបុក៏និយាយអីទេ ព្រួថាអាងត្រ ពាំងថ្មហ្នឹងមានស្លាប់មនុស្សច្រើនណាស់ ដូច្នេះបើមីងថាអត់ស្លាប់មានន័យថា នៅក្នុង របបហ្នឹងអត់មានសម្លាប់មនុស្សទេ ប៉ុន្តែដល់ពេលចប់នេះ ឆ្អឹងគាស់គ្រប់ខេត្តគ្រប់តំបន់ អញ្ចឹងមីង?

ម៉ៅ ៖ ពួកដែលនៅក្នុងនោះហ្នឹងដែលឈឺទៅ គេបញ្ជូនទៅបាត់ៗ មិនដឹងថាងាប់មិនដឹងថារស់ ទេ ។

វណ្ណៈ ៖ បាទៗចុះមានគេដូចថាអ្នក៧/មេសា ធ្វើការមិនគ្រប់គ្រាន់គេម៉ោចាប់អីអញ្ចឹង មានដែរ ឬក៏អត់ទេ?

ម៉ៅ ៖ មានមិនដឹងជាមានទេ ព្រោះគេចាប់មិនដែលឲ្យយើងដឹងទេៗ បើដឹងគេថាបាក់ អារម្មណ៍ទៀតហើយ គេមិនឲ្យដឹងទេ ។

វណ្ណៈ ៖ អញ្ចឹងគេចាប់ពេលយប់អីហ្នឹងមីង?

ម៉ៅ ៖ ចា៎!គេហៅទៅបាត់ទៅ ដូចតែប្តីខ្ញុំអញ្ចឹងគេហៅទៅបាត់ទៅ មិនដឹងថាទៅណាស្រាប់តែ បាត់ ។

វណ្ណៈ ៖ ប្តីមីងទៅណាដែរ ទៅកងចល័តដែរ?

ម៉ៅ ៖ នៅចល័តជុំគ្នារួច ខ្ញុំ ។

វណ្ណៈ ៖ អញ្ចឹងមីងៗទៅកងចល័តហ្នឹងមីងការហើយ?

ម៉ៅ ៖ អត់ទេ!ខ្ញុំទៅនៅនោះហើយ បានខ្ញុំទៅនៅត្រពាំងថ្មបានខ្ញុំបើកវគ្គ ។

វណ្ណៈ ៖ បើកវគ្គប៉ុន្មានគូរទៅ?

ម៉ៅ ៖ ដូចជា១០គូរ ជាង១០គូរនោះ ។

វណ្ណៈ ៖ ឆ្នាំណាទៅ?

ម៉ៅ ៖ មិនដឹងឆ្នាំណាទេបើខ្ញុំម៉ៅមិនដែលបានយកចិត្តទុកដាក់ ។

វណ្ណៈ ៖ មីងទៅដល់ត្រពាំងថ្ម បានប៉ុន្មានខែបើកវគ្គ?

ម៉ៅ ៖ បាន២-៣ខែ បាន៣ខែ ខ្ញុំបើកវគ្គខ្ញុំម៉ៅនេះវិញ ។

វណ្ណៈ ៖ ៣ខែ?

ម៉ៅ ៖ ចា៎!តែខ្ញុំម៉ៅនេះមិនទាន់រួចទេ ។

វណ្ណៈ ៖ ចុះមីងកាលដែលប្ដីមីងស្នេហ៍ហ្នឹង មីងពេញចិត្តដែរអញ្ចឹង?

ម៉ៅ ៖ ចា៎!

វណ្ណៈ ៖ អ្នកស្រុកជាមួយគ្នា?

ម៉ៅ ៖ ទេអ្នកតាវ៉ែង ។

វណ្ណៈ ៖ អញ្ចឹងមីងពេញចិត្តដែរ?

ម៉ៅ ៖ ចា៎!

វណ្ណៈ ៖ បាទ!ដល់ពេលមីងចាប់ផ្ដើមនៅបានរយៈពេលប៉ុន្មាន បានគេចាប់ប្ដីមីងទៅ?

ម៉ៅ ៖ នៅឡើងខ្ញុំទម្ងន់កូននេះកើតបាន៣ខែ នៅបានជាង១ឆ្នាំ មិនបាន២ឆ្នាំទេ ជាង១ឆ្នាំ ។

វណ្ណៈ ៖ ១ឆ្នាំ ប្ដីមីងគេចាប់ដែរឬក៏អត់?

ម៉ៅ ៖ គេចាប់ ។

វណ្ណៈ ៖ អញ្ចឹងបានន័យថា សូម្បីតែប្ដីមីងមួយ មីងទទួលរងគ្រោះបាត់ទៅហើយ អញ្ចឹងអ្នកផ្សេងក៏គេចាប់អញ្ចឹងដែរ អាហ្នឹងជាក់ស្ដែងអញ្ចឹង ហើយបើមីងថាអត់ចាប់ ប្ដីមីងច្បាស់ជានៅហើយ ។

ម៉ៅ ៖ គេចាប់មិនឲ្យយើងឃើញទេ ។

វណ្ណៈ ៖ អញ្ចឹងយើងនិយាយការពិតអញ្ចឹងមីង ប្ដីមីងចាប់ប្រហែលជាឆ្នាំណាមើលទៅ បើមីងថាជិតវៀតណាមចូលហើយ?

ម៉ៅ ៖ ចាប់ជិតវៀតណាមចូល ។

វណ្ណៈ ៖ ពួកនិរតីចូលម៉ៅឬនៅ ពេលចាប់ប្ដីមីង?

ម៉ៅ ៖ និរតីម៉ៅហើយ ។

វណ្ណៈ ៖ អញ្ចឹងប្រហែល៧៨ ចាប់យកទៅណាមីងដឹងទេ?

ម៉ៅ ៖ ទេ!មិនដឹងថាចាប់យកទៅណាទេ ប៉ុន្តែគេថាយកវៃចោល ។

វណ្ណៈ ៖ កាលចាប់ប្ដីមីងហ្នឹង គេចាប់តាក្រុកឬនៅ?

ម៉ៅ ៖ មិនដែលដឹងផង ។

វណ្ណៈ ៖ តាក្រកគណៈឃុំព្រះនេត្រព្រះ?

ម៉ៅ ៖ មិនដឹងថាចាប់ហើយ មិនដឹងថានៅទេបើខ្ញុំមិនដែលបានមកដល់ភូមិ ខ្ញុំនៅតែចល័ត ចល័តម៉ោគេឲ្យនៅហ្នឹងជាប់ ។

វណ្ណៈ ៖ គេចាប់ប្ដីមីងគេចាប់ចេញពីកន្លែងណាទៅ?

ម៉ៅ ៖ ព្រៃមាន់ ។

វណ្ណៈ ៖ ព្រៃមាន់ហ្នឹងគេធ្វើអីទៅ?

ម៉ៅ ៖ ព្រៃមាន់គេជម្លៀសអ្នកនេះទៅ ។

វណ្ណៈ ៖ អញ្ចឹងមីងទៅព្រៃមាន់ជាមួយប្ដី?

ម៉ៅ ៖ ចា៎!

វណ្ណៈ ៖ ទៅធ្វើការអីគេនៅហ្នឹង?

ម៉ៅ ៖ ទៅស្ទូង ។

វណ្ណៈ ៖ ទៅស្ទូង ចាប់ហ្នឹងគេអត់ឲ្យមីងដឹងទេ?

ម៉ៅ ៖ ចា៎!

វណ្ណៈ ៖ ចុះមីងមានតាមសួរគេទេ?

ម៉ៅ ៖ សួរគេ ល្ងាចឡើងក៏រកៗក៏សួរគេ គេថាតែគេចាប់ហើយបាត់ហើយសម័យហ្នឹង ចាប់បាត់ៗ ។

វណ្ណៈ ៖ បាទ!អញ្ចឹងប្ដីមីងកាលហ្នឹងមានតួនាទីដែរបានគេចាប់?

ម៉ៅ ៖ នៅចល័តនៅមានចល័ត ដល់គេម៉ោស្រុកក៏ធ្វើការដូចតែនេះហើយ ចល័តធ្វើប្រធានកងដូចតែខ្ញុំហ្នឹង ប៉ុនដល់ពេលបានខ្ញុំរួចម៉ោនៅភូមិនេះ ធ្វើដូចតែគ្នាហ្នឹង គេប្រើដូចតែគ្នាហ្នឹងឯងមិនបានធ្វើអីទេ ។

វណ្ណៈ ៖ ម៉ោភូមិវិញ?

ម៉ៅ ៖ ចា៎!ម៉ោនេះឯង ម៉ោនេះហើយបានគេជម្លៀសទៅនៅព្រៃមាន់ទាំងអស់គ្នាបានគេ ចាប់ ។

វណ្ណៈ ៖ កាលចាប់ជាមួយប្ដីមីង មានដឹងថាចាប់គ្នាច្រើនទៀតទេ?

ម៉ៅ ៖ គេចាប់មុន គេចាប់ដែរដូចថាគេចាប់ទៅមុនមួយថ្ងៃ ពីរថ្ងៃចាប់បណ្ដើរៗគ្នា ។

វណ្ណៈ ៖ ចាប់បន្តបន្ទាប់គ្នា?

ម៉ៅ ៖ ចា៎!

វណ្ណៈ : អញ្ចឹងខ្ញុំចង់សួរបកម៉ោអាងត្រពាំងថ្មបន្តិចសិន ដូចថាកាលហ្នឹងមីងទទួលបាន១ថ្ងៃ ៧ម៉ែត្រគីបទេ មីងរែកដែរឬក៏មីងគ្រាន់តែថា កាន់មនុស្ស៣០នាក់ហ្នឹងគេគ្រាន់តែឲ្យមីងដើរវាស់ ឬក៏ដើរមើលកូនចៅហ្នឹង?

ម៉ៅ : រែក ។

វណ្ណៈ : រែកដែរ?

ម៉ៅ : ចាំ!រែក មើលកូនចៅផង រែកខ្លួនឯងផង ។

វណ្ណៈ : អញ្ចឹងមីងគិតថាកម្ពស់ដែលយើងរែកឡើងហ្នឹងខ្ពស់ ដែរឬអត់?

ម៉ៅ : ខ្ពស់ ។

វណ្ណៈ : ប្រហែលជាប៉ុន្មានទៅ បើតាមមីងស្មាន?

ម៉ៅ : អេំ!ដូចជាង១០ម៉ែត្រទេដឹង ខ្ពស់ណាស់ ថ្នាំងថ្ម ខ្ញុំមិនសូវចាំទេ ។

វណ្ណៈ : បាទ!កម្ពស់១០ម៉ែត្រ ចុះទទឹងធំទេ?

ម៉ៅ : ធំៗ ។

វណ្ណៈ : ទទឹងអាចបើកឡាន២-៣បានទេ?

ម៉ៅ : អេំ! ប្រហែលឡាន២នោះឯង ប៉ុន្មានសព្វថ្ងៃមិនដឹងយ៉ាងណាទេ ហូរទៅអស់ក៏មិនដឹង ។

វណ្ណៈ : បាទ!អញ្ចឹងតាវ៉ាល់ មានដែលដូចថា ហៅមីងទៅប្រជុំ ហៅមីងម៉ោប្រាប់ពីគោលនយោបាយដឹកនាំឲ្យកម្លាំងហ្នឹងធ្វើការរបៀបម៉េចៗអី ហូបចុកម៉េចអីគាត់មានប្រជុំប្រាប់ទេ?

ម៉ៅ : ប្រជុំៗទាំងអស់គ្នាហ្នឹង ។

វណ្ណៈ : បាទ!ប្រជុំថាម៉េចខ្លះទៅ?

ម៉ៅ : ទេ!ប្រជុំគាត់ថាឲ្យតែខំហ្នឹងហើយ ។

វណ្ណៈ : គាត់កាចទេ?

ម៉ៅ : កាច ។

វណ្ណៈ : បើយើងធ្វើខុសអត់បានទេ?

ម៉ៅ : ចាំ!

វណ្ណៈ : បាទ!ហើយដូចថានៅពេលហ្នឹង ដូចថាកន្លែងសម្រាកអីមានគ្រែ មានខ្នើយអីត្រឹមត្រូវទេ?

ម៉ៅ : គ្មានគ្រែទេ គេធ្វើដំបូលឲ្យនៅដីហ្នឹងឯង ឲ្យតែមាន មុងក៏មិនមាន ។

វណ្ណៈ ៖ មានរោងដេកនៅដី?

ម៉ៅ ៖ ចាំ!មានរោងដេកនៅដី ។

វណ្ណៈ ៖ មានពេទ្យតាមការពារទេ?

ម៉ៅ ៖ ពេទ្យមាន ។

វណ្ណៈ ៖ ពេទ្យហ្នឹងមានប្រសិទ្ធភាពទេ ឲ្យថ្នាំឲ្យអីហ្នឹង?

ម៉ៅ ៖ ថ្នាំគ្រាប់ទន្សាយ ពេទ្យកន្លែងគេ បើពេទ្យនោះដើរមើលៗក៏មានខ្យល់វិលមុខក៏ ។

វណ្ណៈ ៖ ចុះនៅពេលលើកដូចថា នៅពេលលើកៗអញ្ចឹងមីងមានដែលឃើញអ្នកណាដួលសន្លប់អីទេ?

ម៉ៅ ៖ មានៗខ្យល់ ។

វណ្ណៈ ៖ ចុះរហូតដល់ស្លាប់មានទេ?

ម៉ៅ ៖ នៅកន្លែងអត់មានទេ ។

វណ្ណៈ ៖ ដួលសន្លប់អញ្ចឹងគេយកទៅ?

ម៉ៅ ៖ ចាំ!គេយកទៅកន្លែងនោះ ។

វណ្ណៈ ៖ ចុះអ្នក១៧មេសា នឹងអ្នកភូមិអ្នកស្រុកអី អ្នកមូលដ្ឋានហ្នឹងគេក៏រិតស្មើៗគ្នា ឬក៏គេដាក់ទណ្ឌកម្មលើអ្នកមូលដ្ឋានចាស់ ដូចថាអ្នកមូលដ្ឋានថ្មីហ្នឹង២ម៉ែត្រដែរឬក៏ ៣ម៉ែត្រ អ្នកមូលដ្ឋាន អ្នកថ្មី៣ម៉ែត្រក្នុងមួយថ្ងៃ?

ម៉ៅ ៖ ទេ!ដូចកន្លែងខ្ញុំនៅអត់មាន បើមានកម្លាំងទី១ទី២ អានោះមាន ។ មានស្រីកម្លាំងទី ។

វណ្ណៈ ៖ អាំ!ម៉េចទៅស្រីកម្លាំងទី១វិញ?

ម៉ៅ ៖ ស្រីគេមានកម្លាំង ដូចថាអ្នកណាកម្លាំងខ្លាំងដាក់ក្រុមផ្សេង ។

វណ្ណៈ ៖ អញ្ចឹង!គេមើលសាច់ឈាម?

ម៉ៅ ៖ ចាំ!មើលសាច់ឈាម មានៗអាណាគេអ្នកកម្លាំង៣ម៉ែត្រ ដូចអូនឯងថាអញ្ចឹង ពួកខ្ញុំនេះតែ២ម៉ែត្រប៉ុននោះឯង តែ១ម៉ែត្រជាងហ្នឹងមិនចង់បានផង ។

វណ្ណៈ ៖ ចុះឧបមាថាយើងគេវាស់ឲ្យ២ម៉ែត្រ បើយើងមិនហើយយើងឡើងញាំបាយហើយឆ្លៀតពេលធ្វើដល់យប់អីអញ្ចឹង មែនឬក៏មិនមែន?

ម៉ៅ ៖ ទេ!

វណ្ណៈ ៖ ព្រោះស្អែកយើងត្រូវទទួលផែនការណ៍២ម៉ែត្រទៀតហើយ?

ម៉ៅ : ចា៎!ជួនណាគេធ្វើដែរ ជួនណាៗដូចថាពេលណាវារាងធូរទៅអត់អីទេ ជួនណាគេបង្ខំទៅធ្វើម្ដងទៀត បាយរួចទៅម្ដងទៀត ។

វណ្ណៈ : តែបើតាមខ្ញុំដឹងថា ប្រសិនបើយើងមិនខំខ្លួនឯង២ម៉ែត្រហ្នឹង ស្អែកគេត្រូវវាស់២ម៉ែត្រទៀតហើយ ចុះបើ២ម៉ែត្រទៀតយើងមិនខំ យើងមិនហើយ វាមិនស្អែកឡើងកើនៗទៀតយើងមិនស្លាប់យើង?

ម៉ៅ : ចា៎!

វណ្ណៈ : អញ្ចឹងគេថាមានអ្នកខ្លះទៅ មិនហើយអញ្ចឹងឆ្លៀតលួចម៉ោធ្វើដូចថា ម៉ោង៩ឡើងៗ ដល់ពេលមិនហើយ យប់ម៉ោធ្វើឲ្យហើយ ដើម្បីឲ្យស្អែកឡើងយើងបានធូរ២ម៉ែត្រទៀតយើងអាចស្ទួតងើបធ្វើឲ្យបានហើយ?

ម៉ៅ : ចា៎!

វណ្ណៈ : ព្រោះអង្គការដឹងតែបានរួចៗទេ ប្រសិនមិនរួចសុទ្ធតែមានបញ្ហាហើយ ដឹងតែវាស់ថែមៗរហូតអត់មានដកទេ អញ្ចឹងមែនឬក៏មិនមែនទេ?

ម៉ៅ : អញ្ចឹងឯង បើពួកខ្ញុំនេះ២ម៉ែត្រខ្ញុំក្រោកពីយប់ ក្រោកមុនៗម៉ាសន្ទុះទៅវាបានក្រែលគ្រាន់ដែរ នេះជាមួយប្រពន្ធបងឈួងនេះ ។

វណ្ណៈ : បាទ!អាហ្នឹងអញ្ចឹង ប្រសិនបើយើងធ្វើមិនហើយមុនផែនការណ៍ ស្អែកនៅធ្វើមិនហើយទៀត គេនៅតែឲ្យយើងធ្វើអញ្ចឹងដែរឬក៏ម៉េច?

ម៉ៅ : គេឲ្យធ្វើហ្នឹងឯង ។

វណ្ណៈ : ឧបមាថាស្អែកធ្វើមិនហើយ អង្គការបន្ទោសយើងទេ?

ម៉ៅ : ចា៎!បន្ទោស ។

វណ្ណៈ : ចុះបើស្អែកយើងធ្វើមិនហើយទៀតយ៉ាងម៉េច?

ម៉ៅ : គេបន្ទោសហ្នឹងឯង តែបើថាទៅមិនរួចទេ បើថាឈឺក៏ហីទៅ ឈឺទៅឲ្យយើងសម្រាកមួយថ្ងៃ ២ថ្ងៃទៅ រួចទៅមកធ្វើវាស់សារថ្មីម្ដងទៀតទៅ ។

វណ្ណៈ : អញ្ចឹងដូចថាទឹកហូបយ៉ាងម៉េចទៅ?

ម៉ៅ : ទឹកអត់មាន ក្រទឹកណាស់ ។

វណ្ណៈ : ចុះបានងូតទឹកអីដែរ?

ម៉ៅ : ទឹកងូតៗទឹកល្អក់ហ្នឹង ធ្វើអណ្ដូងបុកកាលហ្នឹង មិននដឹងគេធ្វើម៉េច ។

វណ្ណៈ : ប៉ុន្មានថ្ងៃបានងូតទឹកម្ដង?

ម៉ៅ : អ្នកខ្លះទៅមិនផ្ទួតទេ ពួកខ្ញុំផ្ទួតរាល់តែថ្ងៃ ដល់ឡើងពីធ្វើការទៅ ដាក់ដីកគ្រឡុកទៅដាក់ទឹកល្អក់ម៉ៅបុកផ្ទួត ។

វណ្ណៈ : បាទ!ប៉ុនកន្លែងមីងដូចជា ស្តាប់ទៅវារាងធូរជាងកន្លែងផ្សេង ក្រុមផ្សេងគេថាខ្លះរហូតដល់កើតថៃកើតអីនោះ គឺអត់បានផ្ទួតទឹកទេម៉ៅអាទិត្យ២អាទិត្យអី ព្រោះអីទឹករហូតដល់ចែកស្លាបព្រាទៀតដូចមីង គឹម រស់ និយាយគាត់កាន់កងដែរ គាត់និយាយថាចែកស្លាបព្រាគ្នាទៀត បើតាមទឹកម៉ៅបំពង់ហ្នឹងម៉ៅត្រូវផឹកតែឯង សឹងតែទាំងអស់ហើយ ប៉ុនរហូតដល់អត់មានទឹកចែកស្លាបព្រាគ្នាទៅ ដើម្បីឲ្យមានជាតិទឹកចូល?

ម៉ៅ : ទឹកមិនមានទេ ទឹកមកដល់ត្រពាំងថ្មនេះ ។

វណ្ណៈ : ហ្នឹងហើយ ហើយថាមានឡានដឹកទឹកអីឲ្យវាមិនគ្រាន់ទេ ព្រោះថាមនុស្សវាខ្លាប់ទឹកខ្លាប់ដីណាស់ច្រើន អញ្ចឹងមែនឬក៏?

ម៉ៅ : មនុស្សច្រើនណាស់ ដណ្តើមគ្នាដាក់ អ្នកណាទាន់ក៏ទាន់ទៅ អ្នកណាមិនទាន់ក៏អត់ បើយើងអ្នក ដូចថាជិតស្និតគ្នាទៅក៏បានទៅ គេទៅយកបានទៅក៏បានចែកគ្នាទៅ មកដល់ត្រពាំងថ្មដងកំប៉ុងទឹកអត់មានទេ ។

វណ្ណៈ : អញ្ចឹងដូចថា កាលហ្នឹងដូចឃើញមានប្រដាប់រុញដីរបស់ចិនរបស់អីនោះមានទេ?

ម៉ៅ : ទេ!មិនដែលឃើញមានទេ លើកតែកម្លាំងទេ ។

វណ្ណៈ : លើកតែកម្លាំងឡើងទៅ ប៉ុន្តែមានអាប្រដាប់ឈូសអីនោះ?

ម៉ៅ : ទេ!ធ្វើតែខ្លួនឯង ។

វណ្ណៈ : ធ្វើចប ធ្វើអីទៅ?

ម៉ៅ : ចា៎!ធ្វើចបគេបុក ប្រុសៗទៅគេចេះទៅគេធ្វើសំអាតទៅ គ្មានស្តីទេមិនដែលស្គាល់ឡានទេ ។

វណ្ណៈ : ចុះកាលមីងនៅធ្វើហ្នឹងយាយចែម អីបានទៅមើលនៅហ្នឹងឬអត់?

ម៉ៅ : មិនដែលស្គាល់ទេ ។

វណ្ណៈ : មិនដែលស្គាល់ទេ?

ម៉ៅ : ចា៎!

វណ្ណៈ : ស្គាល់តែតាវ៉ាល់មួយ?

ម៉ៅ : ស្គាល់តែតាវ៉ាល់មួយ យាយចែម ទាល់តែខ្ញុំមកភូមិនេះ ដល់នៅព្រៃមាន់បាន ឃើញ ។

វណ្ណៈ : អញ្ចឹងមីងចេញពីទំនប់អាងត្រពាំងថ្ម ទៅព្រៃមាន់?

ម៉ៅ ៈ ចា៎! ម៉ោនេះឯងម៉ោភូមិ ម៉ោដូនជ្រែង ។

វណ្ណៈ ៈ ភូមិដូនជ្រែងនេះយាយថែម ម៉ោនេះ?

ម៉ៅ ៈ ទេ! ម៉ោពីដូនជ្រែង ពួកខ្ញុំម៉ោពីដូនជ្រែងហ្នឹងគេជម្លៀសទាំងភូមិនេះ ទាំងអស់គ្នាទៅនៅព្រៃមាន់ ។

វណ្ណៈ ៈ អញ្ចឹងចេញពីអាងត្រពាំងថ្មម៉ោក្នុងភូមិ?

ម៉ៅ ៈ ចា៎!

ជិតខាង ៈ យាយថែម ដល់ជម្លៀសពីនេះទៅបានឃើញ ។

ម៉ៅ ៈ ចា៎! ឃើញនៅព្រៃមាន់ ។

វណ្ណៈ ៈ ក្នុងភូមិហ្នឹងបានរយៈពេលប៉ុន្មាន បានគេបញ្ជូនទៅ ទាំងអស់ទាំងម៉ាភូមិហ្នឹងហ្នង?

ម៉ៅ ៈ ទាំងអស់ហ្នឹងឯង ។

វណ្ណៈ ៈ រយៈពេលប៉ុន្មានគេជម្លៀសទៅព្រៃមាន់ កាលនៅក្នុងភូមិ?

ម៉ៅ ៈ ម៉ោនៅដូចជា៥-៦ខែ ។

វណ្ណៈ ៈ ខែណា ខែវស្សាឬខែប្រាំង?

ម៉ៅ ៈ ខែភ្ជួរនេះឯង ។

ជិតខាង ៈ ខែឃើងដាំពោត ដាំសណ្តែក ។

ម៉ៅ ៈ ចា៎! ខែពិសាខខែអីនេះឯង គេជម្លៀសទៅ ដាំរួចទៅ ។

វណ្ណៈ ៈ ខែដាំពោត?

ម៉ៅ ៈ ចា៎!

វណ្ណៈ ៈ ពេលមីងម៉ោនៅក្នុងភូមិ មីងឈប់កាន់មនុស្សកាន់កងទៀតនៅ?

ម៉ៅ ៈ ឈប់ហើយ ខ្ញុំទម្ងន់ ។

វណ្ណៈ ៈ ហើយម៉ោនៅក្នុងភូមិហ្នឹងហូបចុកយ៉ាងម៉េចដែរ ហូបអីហូបបាយឬហូបបបរ?

ម៉ៅ ៈ ហូបបបរ ។

វណ្ណៈ ៈ គេចែកយ៉ាងម៉េចដែរ?

ម៉ៅ ៈ ម៉ាវែក ។

វណ្ណៈ ៈ អញ្ចឹងមានមនុស្សស្លាប់ដោយសារអត់អាហារទេ នៅក្នុងភូមិហ្នឹង?

ម៉ៅ ៈ មាន ។

ជិតខាង ៈ ស៊ីតែពីតែពាសស៊ីដើមផ្សិត ផ្សិតពុលស៊ីទៅក៏ពុកក៏មានដែរ ។

វណ្ណៈ : អញ្ចឹងមីងម៉ោក្នុងភូមិវិញ តើប្រជាជនថ្មីប្រជាជនអីក៏មានស្លាប់ច្រើនដែរ?

ម៉ៅ : មានៗ

វណ្ណៈ : ស្លាប់ច្រើនដោយសារអត់អាហារមែនទេ?

ម៉ៅ : ចា៎!

វណ្ណៈ : អញ្ចឹងដែលឃើញប្រជាជនដើរចាប់កណ្តូប ចាប់សត្វអីស៊ីតែពីតែពាស?

ម៉ៅ : ចាប់ៗទាំងប្រជាជនថ្មី ទាំងចាស់ហ្នឹងឯង ទាំងអស់គ្នាហ្នឹងឯងៗ

វណ្ណៈ : មីងអីក៏ពិបាកដែរ?

ម៉ៅ : ពិបាក លួចបូតស្រូវៗ

វណ្ណៈ : លួចបូតស្រូវយ៉ាងម៉េចទៅ?

ម៉ៅ : ទៅលួចបូតស្រូវគេយកស៊ីៗ

វណ្ណៈ : អញ្ចឹងមានដែលគេចាប់បានទេ?

ម៉ៅ : គេចាប់បាន ព្រោះខ្ញុំទម្ងន់ក៏គេមិនធ្វើអីដែរ ទម្ងន់ក៏ទៅឃ្លានៗ

វណ្ណៈ : អញ្ចឹងនៅក្នុងភូមិហ្នឹងពីណាប្រធានសហករណ៍?

ម៉ៅ : តាពៅៗ

វណ្ណៈ : ឥឡូវគាត់ស្លាប់ឬក៏នៅរស់?

ម៉ៅ : ចា៎!ស្លាប់ហើយ ស្លាប់ដែលនិរតីចុះម៉ោៗ

វណ្ណៈ : និរតីចុះម៉ោចាប់គាត់?

ម៉ៅ : ចា៎!

វណ្ណៈ : ចុះតាក្រក គេចាប់ដែរ?

ម៉ៅ : គេចាប់ស្រករៗគ្នាហ្នឹង ដែលនិរតីម៉ោៗ

វណ្ណៈ : គណៈឃុំតាក្រក ពេលហ្នឹង?

ម៉ៅ : ចា៎!គណៈឃុំតាក្រក ហ្នឹងៗ

វណ្ណៈ : ទៅព្រៃមាន់ហ្នឹង មីងមានជួបយាយថែម ទេ?

ម៉ៅ : ជួបដែលម៉ោព្រៃមាន់ៗ

វណ្ណៈ : យាយថែម មានដែលប្រជុំប្រាប់ថាយ៉ាងម៉េចទេ?

ម៉ៅ : អត់បានប្រជុំទេ ប្រជុំតែសហករណ៍គេ ប្រធានសហករណ៍ៗ

វណ្ណៈ : ប្រធានសហករណ៍ឈ្មោះអីនៅនោះ?

ម៉ៅ : ឈ្មោះ តាទឹម ។

វណ្ណៈ : ទឹមហ្នឹងកាចទេ?

ម៉ៅ : កាច ។

វណ្ណៈ : ម៉ៅពីនិរតី?

ម៉ៅ : និរតី ។

វណ្ណៈ : អញ្ចឹងនៅក្នុងភូមិហ្នឹងជម្លៀសទៅព្រៃមាន់ទាំងអស់គ្នា?

ម៉ៅ : ចា៎!

វណ្ណៈ : អត់មានសល់ទេ?

ម៉ៅ : អត់ ។

វណ្ណៈ : អញ្ចឹងគេយកភូមិនេះធ្វើអី?

ម៉ៅ : ភូមិហ្នឹងទុកចោល ។

វណ្ណៈ : ភូមិនេះទុកចោល?

ម៉ៅ : ចា៎!ទុកចោល ។

វណ្ណៈ : ពេលមីងទៅព្រៃមាន់ហ្នឹងជួបយាយថែម១ ដែលប្រជុំប្រាប់ថាម៉េច១ខ្លះទេ?

ម៉ៅ : មិនដែលឃើញយាយថែម ប្រជុំទេ ប្រជុំតែតាទឹមហ្នឹងឯង ។

វណ្ណៈ : ប៉ុនឃើញយាយថែម ទៅដែរ?

ម៉ៅ : ឃើញទៅ ។

វណ្ណៈ : បាទ!ទៅព្រៃមាន់ហ្នឹង មីងទៅដកស្ទូងទេ?

ម៉ៅ : ចា៎!

វណ្ណៈ : ហើយមីងនៅហ្នឹងគេឲ្យហូបចុកយ៉ាងម៉េចដែរ?

ម៉ៅ : បបរ ។

វណ្ណៈ : ពិបាកទេ?

ម៉ៅ : ពិបាក បបរមួយវែក ។

វណ្ណៈ : ម្នាក់មួយវែក?

ម៉ៅ : ចា៎!

វណ្ណៈ : អញ្ចឹហនៅហ្នឹង មានប្រជាជនគេស្លាប់ច្រើនទេ?

ជិតខាង : ស្លាប់ច្រើន ដោយសារតែតាទឹម ហ្នឹងឯង ។

វណ្ណៈ : ប្តីមីងស្លាប់នៅហ្នឹងដែរ?

ម៉ៅ : ចា៎!

វណ្ណៈ : មីងអត់ដឹងថាប្តីមីងគេចាប់ដោយសាររឿងអីទេ?

ម៉ៅ : អត់ដឹងទេ ។

វណ្ណៈ : មីងអត់ហ៊ានសួរគេទេ គេចាប់ខ្លួនបាត់ទៅមីងទៅសួរគេ?

ម៉ៅ : អត់ហានសួរគេទេ ។

វណ្ណៈ : អត់សួរតាទីម ហ្នឹងថាប្តីទៅណាអីទេ?

ម៉ៅ : ទេ!អត់ហានសួរទេ ខ្លាចគេសម្លាប់ចោល ។

វណ្ណៈ : អញ្ចឹងនៅក្នុងភូមិហ្នឹងក្រៅពីប្តីមីងមានគេចាប់មនុស្សផ្សេងៗទៀតទេ?

ម៉ៅ : មាន អ្នកទៅពិនេះដូចតែគ្នាហ្នឹង គេថាឯងធ្វើទាហានធ្វើអី ។

វណ្ណៈ : អញ្ចឹងមីងធ្វើទាហានដែរ?

ម៉ៅ : អត់!បើខ្ញុំមិនដែលស្គាល់ផង បើនៅស្រុកតាវ៉ែង នោះប៉ុនខ្ញុំសួរគេថា ឪធ្វើទាហាន កូនមិនបានធ្វើទេ ។

វណ្ណៈ : អញ្ចឹងគេស្រាវជ្រាវអញ្ចឹង?

ម៉ៅ : ចា៎!

វណ្ណៈ : អញ្ចឹងកាលជំនាន់តាក្រក ហើយនឹងជំនាន់យាយថែម ហ្នឹងការស្លាប់មនុស្សហ្នឹងវាប្រហាក់ប្រហែលគ្នាឬក៏ជំនាន់យាយថែម ស្លាប់មនុស្សច្រើនជាង?

ម៉ៅ : យាយថែម ហើយនឹងនិរតីហ្នឹង ។

វណ្ណៈ : ហ្នឹងហើយយាយថែម ខាងនិរតី ជំនាន់តាក្រក តាវ៉ាល់ហ្នឹងស្លាប់មនុស្សច្រើនដែរឬក៏ជំនាន់យាយថែម ម៉ៅពីនិរតីស្លាប់មនុស្សច្រើនជាង?

ម៉ៅ : ខ្ញុំថាដូចជានិរតីច្រើនជាង ។

វណ្ណៈ : ស្លាប់ច្រើនជាង?

ម៉ៅ : ចា៎!កាលនោះនៅនេះគេបើកអង្ករឲ្យ បើកអង្ករ បើកបាយ ។

វណ្ណៈ : បាទ!អាហ្នឹងជំបូងទេ?

ម៉ៅ : ចា៎!

វណ្ណៈ : តែក្រោយម៉ោ៧៦អីហ្នឹង គេសហករណ៍រួម បាយរួមអស់ហើយ?

ម៉ៅ : ចា៎!បាយរួមមែន ប៉ុនបាយ ។

វណ្ណៈ : បាទ!មីងនៅតាមកងចល័តទេ ចល័តតំបន់?

ម៉ៅ : ចា៎!

វណ្ណៈ : តែអ្នកទៅក្នុងភូមិបរពុថាអញ្ចឹង ហើយមែនឬអីអ្នកក្នុងភូមិពុថា ក្បាលជន្លង់ប៉ុនណាណីនោះ?

ម៉ៅ : ខ្ញុំមិនបាននៅក្នុងភូមិទេ ។

វណ្ណៈ : បាទ!មិនបាននៅក្នុងភូមិទេ ។ កាលហ្នឹងមីងចល័តតំបន់ៗប៉ុន្មានមីងនៅហ្នឹង?

ម៉ៅ : គេហៅតំបន់៥ ។

វណ្ណៈ : ពេលប្ដីមីងចាប់ហើយ ប៉ុន្មានខែប៉ុន្មានឆ្នាំបានវៀតណាមចូលម៉ៅ?

ម៉ៅ : មើល៍!ចប់ខែវស្សា ខែវស្សាចប់ ខែច្រូតវៀតណាមចូល ខែបិណ្ឌខែអីហ្នឹងឯង ។

វណ្ណៈ : បាទ!ចុះមីងនៅព្រៃមាន់ហ្នឹង មីងធ្វើអីខ្លះមីងអាចរៀបរាប់បានទេ និយាយទៅៗរៀបរាប់ទៅថាទៅធ្វើអីខ្លះ នៅកន្លែងណាអីកន្លែងណាអីអញ្ចឹង?

ម៉ៅ : នៅព្រៃមាន់គេឲ្យទៅតែស្ទូង ស្ទូងរួចក៏ច្រូត ច្រូតស្រូវហ្នឹង ដល់ពេលច្រូចបានខ្លះហើយក៏វៀតណាមចូល ហើយខ្ញុំសរសៃខ្ចីផង ។

វណ្ណៈ : អ្ហូ!មីងសម្រាលកូនហើយប៉ុន្មានខែ គេឲ្យចុះច្រូត?

ម៉ៅ : ១ខែជាង គេឲ្យស្ទូង ។

វណ្ណៈ : ចុះកូនមីងគេឲ្យយកទៅណាវិញ?

ម៉ៅ : កូនក៏មានយាយ គេមើល ។

វណ្ណៈ : យាយៗមើល ល្ងាចបានជួបកូន?

ម៉ៅ : ទេ! ព្រឹកចេះមៅ១១ម៉ោវិញ មកឲ្យកូនមឹម យើងហូបបាយនោះ ដល់ពេលម៉ោង១ទៅវិញ ។

វណ្ណៈ : ចុះបើមីងហូបបបរមិនឆ្អែតផង ទំរាំឲ្យកូនមឹមទៀត រឹតតែអស់កម្លាំង?

ម៉ៅ : បេះត្រកួន បេះព្រលិច ច្រិចអីទៅណាស្ងោទៅ ថាតែមិនរស់ ចេះបានរស់មកដល់សព្វថ្ងៃ ។

វណ្ណៈ : បាទ!ពេលគេចាប់ប្ដីមីងហើយ មីងភ័យខ្លាំងទេ?

ម៉ៅ : ភ័យ! ខ្ញុំគ្រុនមិនគ្រុន អាឈឺមិនឈឺ ឆាប់ងាប់សរសៃខ្ចីផង គេថារករឿងគេសម្លាប់ទាំងអស់ ខ្ញុំភ័យរត់ដេកផ្ទះគេផ្ទះឯងតែពាស ។

វណ្ណៈ : ចុះកាលហ្នឹងដូចថា មីងដែលឃើញប្រជាជនថ្មីអីគេចាប់ចងចាប់អីមីងដែលឃើញ?

ម៉ៅ ៖ ទេ!មិនបានឃើញទេ មានគេចាប់ប៉ុនខ្ញុំអត់ដែលបានឃើញ ។

ជិតខាង ៖ មិនបានឃើញទេ វាមានគេចាប់ប៉ុនមិនហានទៅជួយ អត់ហានធានា អត់ហានអះអាង បើឃើញម្នាក់ៗ ឃើញភ័យរៀងខ្លួន ព្រោះថាគេឃើញហៅទៅបាត់ៗ បានសេចក្ដីថា គេយកទៅសម្លាប់ ។

វណ្ណៈ ៖ អ្នកភ្នំពេញអ្នកអីគេជម្លៀសម៉ោច្រើន?

ម៉ៅ ៖ ច្រើន ។

វណ្ណៈ ៖ ច្រើន ហើយបានត្រឡប់ទៅវិញច្រើនឬក៏បានទៅវិញបានតិចតួចទេ?

ម៉ៅ ៖ មិនដឹងយ៉ាងណា បើបែកគ្នា អ្នករត់ច្រើនរត់ទៅតំបន់៣ ។

ជិតខាង ៖ បើគ្រោះថ្នាក់ ច្រើនគ្រោះថ្នាក់នៅព្រៃមាន់ ។

វណ្ណៈ ៖ នៅព្រៃមាន់ហ្នឹងច្រើនហ្មង?

ម៉ៅ ៖ ចា៎!នៅព្រៃមាន់ច្រើន តែអ្នកភ្នំពេញនេះច្រើនរត់ទៅត្រើយម្ខាង ។

វណ្ណៈ ៖ រត់ទៅខាងណាវិញ?

ម៉ៅ ៖ រត់ទៅតំបន់៣ ។

វណ្ណៈ ៖ រត់រួច?

ម៉ៅ ៖ ចា៎!រត់ទៅ អ្នកដែលនៅនេះរត់ទៅៗ បានរស់ច្រើន ។

វណ្ណៈ ៖ ម៉េចបានរត់ទៅបាន?

ម៉ៅ ៖ តែឆ្លងស្ទឹងហើយៗ ។

វណ្ណៈ ៖ ស្ទឹងនៅខាងណាទៅ?

ម៉ៅ ៖ ស្ទឹងនៅខាងហ្នឹងហើយ ។

វណ្ណៈ ៖ ហើយយើងទៅធ្វើការៗ រត់ទៅតំបន់៣?

ម៉ៅ ៖ ចា៎!រត់ទៅនោះយើងបាយៗ ។

វណ្ណៈ ៖ អញ្ចឹងរត់ទៅខាងនោះគេអត់សម្លាប់យើងអញ្ចឹង?

ម៉ៅ ៖ អត់ទេ ។

វណ្ណៈ ៖ ខាងនេះអត់ទៅតាមទេ?

ម៉ៅ ៖ អត់ហានតាមទេ ទៅដល់កន្លែងគេតែឆ្លងស្ទឹងហើយៗ ។

វណ្ណៈ ៖ អញ្ចឹងមានឈ្លបយាមតាមស្ទឹងទេ?

ម៉ៅ ៖ មានខ្លះដែរ ប៉ុនដូចថាភ្លាត់ទៅវាចេះតែទៅបានហើយ ។

វណ្ណៈ : យប់អីអញ្ចឹង?

ម៉ៅ : ចា៎! ទៅបាន ។

វណ្ណៈ : ចុះបើយើងរត់ៗទៅបានតែឯង ហើយបើឪពុកម្ដាយយើងនៅនេះតែឯងអញ្ចឹង យើងធ្វើម៉េចទៅ គេមិនចាប់ឪពុកម្ដាយ?

ម៉ៅ : អត់ទេ!ជួនណារត់ទៅតែឯង ជួនណាប្ដីប្រពន្ធកូនទៅទាំងអស់ទៅ ។

វណ្ណៈ : រត់ទៅគេអត់ធ្វើបាបទេ?

ម៉ៅ : ចា៎! នៅនោះបានរស់ច្រើន បើនៅនេះដឹងតែស្លាប់ហើយ ។

វណ្ណៈ : គ្រាន់តែតំបន់៣ ហើយនឹងតំបន់៥ហ្នឹងក៏ខុសគ្នាដែរហ្ចបចុក?

ជិតខាង : មកពីមូលហេតុអ្នកដឹកនាំ ។

វណ្ណៈ : អញ្ចឹងម៉ោពីអ្នកដឹកនាំទេ?

ម៉ៅ : ចា៎!

វណ្ណៈ : អញ្ចឹងមីងគិតថាមានថ្នាក់លើដាក់កំរិតម៉ោទេអញ្ចឹង?

ម៉ៅ : មិនដឹងយ៉ាងណាបានជាគេរត់ ពួកខ្ញុំនេះថានឹងរត់គេទៅ រត់ទៅតំបន់៣នោះ ។

វណ្ណៈ : បាទ!អញ្ចឹងតំបន់៣ហ្នឹងធូរជាងគេ?

ម៉ៅ : ចា៎!

វណ្ណៈ : អញ្ចឹងនៅហ្នឹងមានប៉ុន្មានតំបន់មីងមានដឹងទេ មានតំបន់៣ តំបន់៥ តំបន់៤នៅខាងណាវិញ?

ម៉ៅ : តំបន់៤នៅណាឯង(គាត់សួរប្ដីគាត់) ។

វណ្ណៈ : បាទ!មីងអត់បានដឹងទេ?

ម៉ៅ : ចា៎!មិនបានដឹងទេ ។

វណ្ណៈ : អញ្ចឹងតំបន់១ខាងណាវិញ?

ម៉ៅ : មិនដែលដឹងទេ ដឹងតែ២នេះហើយ ។

វណ្ណៈ : ចុះតំបន់៣?

ម៉ៅ : តំបន់៣នៅឯត្រើយម្ខាងហ្នឹង ។

វណ្ណៈ : តំបន់២អត់ដឹងដែរ?

ម៉ៅ : អត់ ។

វណ្ណៈ : ចុះគេថាតំបន់៦ តំបន់៧ឯណាទៀតនោះ?

ម៉ៅ ៖ នៅណាទេ នៅនោះមិនដឹង ម៉ាដួរណែ៎ក្រឡាញ់នោះអីដឹង ។

វណ្ណៈ ៖ ចុះមីងគិតថាដូចថា នៅក្នុងសម័យខ្មែរក្រហមហ្នឹងធ្វើឲ្យប្រជាជនអត់បាយ អត់អីហ្នឹង តើមីងគិតថាថ្នាក់លើឬក៏អី ដែលដាក់បញ្ជាម៉ោឲ្យធ្វើអញ្ចឹង ឬក៏មីងគិតថាពួកថ្នាក់ក្រោមហ្នឹងធ្វើដោយខ្លួនឯង?

ម៉ៅ ៖ មិនដឹងទេ ។

វណ្ណៈ ៖ ហើយចុះដូចថាស្រូវអង្ករអី ស្ទូងបានច្រើនទេ?

ម៉ៅ ៖ ស្ទូងបានៗ ទៅគេដាក់ជង្រុក បានគេដាក់ទុកទៅក៏គេបើករបប បបរឲ្យទៅ មិនដឹងថាគេយកទៅណាខ្លះស្រូវ ។

ជិតខាង ៖ ភូមិដូចជ្រែង ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះផ្នែកខាងស្រូវអង្ករច្រើនតែមាន ជង្រុក ប៉ុន្តែអត់មានការហូបចុក ។

វណ្ណៈ ៖ អញ្ចឹងស្រូវអង្ករមានច្រើនដែរ ប៉ុន្តែគេមិនឲ្យយើងហូបគ្រប់គ្រាន់ទេ?

ម៉ៅ ៖ ចា៎!អត់ ។

វណ្ណៈ ៖ ឧបមាថាដាំណាំមីងដាំក្នុងផ្ទះបានដូចជា ខ្ទឹម ល្ពៅអីអញ្ចឹងអាចបេះហូបខ្លួនឯងបានទេ?

ម៉ៅ ៖ ក្នុងផ្ទះបើចំហៀងនេះបាន ។

វណ្ណៈ ៖ អញ្ចឹងគេអត់ថាអីទេ?

ម៉ៅ ៖ ចា៎! បើទៅក្រៅដាក់រួម ។

វណ្ណៈ ៖ ចុះបើក្នុងផ្ទះយើងដាំបានអញ្ចឹង យើងមិនដាំឲ្យច្រើនទៅទុកហូប?

ម៉ៅ ៖ ដាំឯណាទឹកលិចហ្នឹង ។

វណ្ណៈ ៖ ទឹកលិច?

ម៉ៅ ៖ ទឹកលិចដីអស់ នេះកុំតែចាក់ដីទេ កុំអីដែលដាំកើត ខែវស្សាទឹកលិចអស់រលីង ។

វណ្ណៈ ៖ អញ្ចឹង ចុះឥឡូវមានទឹកធំទៀតទេ?

ម៉ៅ ៖ មានទឹកយ៉ាងណាបើលើកដីអស់ហើយ ។

វណ្ណៈ ៖ បាទ!តែជំនាន់ខ្មែរក្រហមលិចនៅក្នុងភូមិទៀត?

ម៉ៅ ៖ លិចក្នុងផ្ទះខ្ញុំមិនដែលមាននៅទេ លិចរាល់តែវស្សា ។

វណ្ណៈ ៖ ចុះឧបមាថាយើងចាប់ត្រីចាប់អីបានទេ បើទឹកច្រើនអញ្ចឹងយើងមានត្រីមានអី?

ម៉ៅ ៖ បានៗ ។

វណ្ណៈ ៖ អង្ករអត់មានថាអី?

ម៉ៅ ៖ ទេ!ស្អូចមានអីបាន បើថាទៅរកនោះដាក់រួមគេ បើសិនជាជីដូចសព្វថ្ងៃនេះ ខ្ទះអីហូប ចេកទៅអីទៅ ដល់ពេលសម័យនោះខែវស្សាលិចអស់ មានតែត្រកួនហើយព្រលិត ហ្នឹង ។

វណ្ណៈ ៖ អញ្ចឹងមីងនៅព្រៃមាន់រហូតដល់៧៩ ដល់ពេលវៀតណាមចូលបានត្រឡប់ម៉ៅភូមិដូនជ្រែងវិញ?

ម៉ៅ ៖ ចាំ!

វណ្ណៈ ៖ ពីហ្នឹងទៅភូមិដូនជ្រែងដូចថា ឆ្ងាយពីគ្នាទេ?

ម៉ៅ ៖ ពីដូនជ្រែង ទៅព្រៃមាន់?

វណ្ណៈ ៖ បាទ!?

ម៉ៅ ៖ គ្មានឆ្ងាយណាទេ ។

វណ្ណៈ ៖ មីងអាចដើរ?

ម៉ៅ ៖ ដើរដល់ប៉ុនគេមិនឲ្យម៉ៅហ្នឹង ។

វណ្ណៈ ៖ ដើរមួយថ្ងៃដល់ទេ?

ម៉ៅ ៖ ទេ!ដើរអត់ដល់មួយថ្ងៃទេ ប៉ុនគេមិនឲ្យម៉ៅ តែម៉ៅចាប់ឯងចង ។

វណ្ណៈ ៖ មីងអត់ដឹងថាគេជម្លៀសទៅ នៅកន្លែងហ្នឹងគេយកទៅធ្វើអីទេ?

ម៉ៅ ៖ ចាំ! គេទៅរកដីគោក ឯនេះវាទឹក ។

វណ្ណៈ ៖ ចុះពេលវៀតណាមចូលម៉ៅឆ្នាំ៧៩ហ្នឹង តើមីងរត់ភៀសខ្លួនទៅជាយដែនដែរឬមិន ទេ?

ម៉ៅ ៖ អត់! អត់ទេនៅតែនេះ ។

វណ្ណៈ ៖ រត់ម៉ៅផ្ទះវិញ?

ម៉ៅ ៖ ចាំ!

វណ្ណៈ៖ ចុះពួកនិរតីអត់មានផ្ដួងមីង បង្ខំមីងឲ្យទៅព្រៃទេ?

ម៉ៅ ៖ ទេនិរតីទៅផុតអស់ ។

វណ្ណៈ ៖ ម៉េចបានវាទៅមុនអញ្ចឹង?

ម៉ៅ ៖ កាលនៅព្រៃមាន់នោះ នៅព្រៃមាន់ពួកខ្ញុំនៅព្រៃមាន់រួចហើយវាកើតឲ្យទៅនោះ ដល់ទៅដល់ត្រពាំងថ្មពួកខ្ញុំរត់ម៉ៅវិញ ។

វណ្ណៈ ៖ បាទ!អញ្ចឹងពេលមីងរត់ម៉ៅវិញ មីងរស់នៅក្នុងភូមិធ្វើស្រែចំការអញ្ចឹងទៅ?

ម៉ៅ ៖ ចាំ!

វណ្ណៈ ៖ ហើយចុះមីងមានអីចង់និយាយអីទៀតទេមីង?

ម៉ៅ ៖ គ្មានអីនិយាយទៀតផង ។

វណ្ណៈ ៖ អញ្ជើងខ្ញុំអរគុណមីងច្រើន ។

ម៉ៅ ៖ ចាំៗ !

«ចប់»